ស-សបាសាក់ SA SA BASSAC

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

+855 (0)77 374 110
www.sasabassac.com

# សេចក្តីប្រកាសព័ត៌មាន

សំរាប់ការផ្សាយបន្ទាន់
ថ្ងៃព្រហស្បតិ៍ ទី ៣១ ខែ មីនា ឆ្នាំ ២០១១

## ស-សបាសាក់ សូមបង្ហាញជូននូវពិព័រណ៍សិល្បៈក្រោមចំណងជើងថា *ការចងចាំ* ដោយ យឹម ម៉ាលីន



*ស្នាមរបួស ២*, ២០១១, ខ្មៅដៃលើក្រដាស, 110 x 79.5cm



*ស្នាមរបួស 3*, ២០១១, ខ្មៅដៃលើក្រដាស, 110 x 79.5cm

**ភ្នំពេញ** - ស-សបាសាក់ សូមជម្រាបជូនដំណឹងស្តីអំពីពិព័រណ៍សិល្បៈរបស់សិល្បការិនី យឹម ម៉ាលីន ក្រោមចំណងជើងថា «*ការចងចាំ*» ។ ពិព័រណ៍ *ការចងចាំ* នឹងបង្ហាញជូននូវស្នាដៃពណ៌សខ្មៅចំនួនបួនប្រភេទស្តីពីការចងចាំរបស់ម៉ាលីនកាលពីកុមារភាព ដែលក្នុងនោះភាពសប្បាយរីករាយនិងក្តីព្រួយបារម្ភនៅលាយឡំគ្នា។

ម៉ាលីន ខិតខំធ្វើការងារសិល្បៈយ៉ាងហ្មត់ចត់បំផុត ដោយប្រើប្រាស់នូវសម្ភារៈផ្សេងៗចំរុះគ្នា ហើយពិនិត្រពិច័យយ៉ាងល្អិតល្អន់លើទស្សនៈដ៏ស្មុគស្មាញស្តីពី *សេរីភាព* ។ ម៉ាលីន ធំដឹងក្តីក្រោយការដួលរលំជាផ្លូវការនៃរបបខ្មែរក្រហម ហើយរយៈពេលប៉ុន្មានឆ្នាំក្នុងវ័យកុមាររបស់ម៉ាលីន តាមបរិបទនយោបាយ គេចាត់ទុកថាវាជាពេលវេលាដែលប្រកបដោយសេរីភាព ។ ម៉ាលីន នៅចាំថាបានលេងនិងសើចសប្បាយ ដែលសកម្មភាពទាំងនេះត្រូវបានគេហាមឃាត់នៅអំឡុងពេលប៉ុន្មានឆ្នាំមុនពេលនាងបានកើត ។ ប៉ុន្តែទន្ទឹមនឹងនេះ ម៉ាលីនក៏នៅចាំបានដែរអំពីបរិយាកាសទ្បោមព័ទ្ធទៅដោយអំពើហឹង្សា ភាពក្រលំបាកវេទនា និងភាពទ្រុឌទ្រោមនៃហេដ្ឋារចនាសម្ព័ន្ធសង្គម ។

នៅក្នុងអត្ថបទមួយដែលមានចំណងជើងថា *អ្វីទៅជាសេរីភាព?* អ្នកនាងហាណ្ណា អារិន្ត បានសរសេរថា «បទពិសោធន៏នៃសេរីភាព គឺកើតចេញពីអ្វីដែលគេសន្មតទុកជាមុនថា ជាការគេចចេញពីពិភពដែលសេរីភាពមិនត្រូវ

បានគេផ្តល់ឲ្យ ទៅរកកន្លែងមួយនៅក្នុងចិត្តរបស់ខ្លួនឯងផ្ទាល់ ដែលមិនមានអ្នកណាផ្សេងអាចចូលទៅដល់» ។ ម៉ាលីន បានរិះរកវិធីដើម្បីប៉ះប៉ូវអតីតកាលរបស់នាង តាមរយៈការស្រមើស្រមៃនៅក្នុងចិត្ត ហើយប្រឌិតឡើងនូវអ្វីមួយដែលការពិតមិនមាននោះទេ ។ ម៉ាលីន លើកឡើងថា «សង្គ្រាមផ្តល់នូវផលលំបាក ។ យើងទាំងអស់គ្នាចង់បាននូវសេរីភាព តែយើងមិនដឹងថាគេនឹងផ្តល់សេរីភាពនោះអោយយើងដែរឬអត់នោះទេ ។ ការងារសិល្បៈអាចជួយអោយខ្ញុំផ្តល់នូវសេរីភាពដល់ខ្លួនឯងបាន ។ ប្រសិនបើមានអ្វីមួយដែលខ្ញុំមិនពេញចិត្តនៅក្នុងពិភពជាក់ស្តែង ខ្ញុំអាចប្រឌិតវាឡើងវិញតាមរយៈស្នាដៃសិល្បៈរបស់ខ្ញុំ ហើយខ្ញុំនៅតែបន្តលេងសើចសប្បាយ និងចង់ដឹងចង់ឃើញដូចជាកាលនៅវ័យកុមារអញ្ចឹងដែរ ។»

ម៉ាលីន បានប្រែក្លាយផ្ទះបាយដ៏ចាស់របស់គ្រួសារនាង ទៅជាកន្លែងលេងកំសាន្តមួយដ៏ចម្លែក។ *បាយឡុកបាយឡ* (២០១០) គឺជាស្នាដៃបែប Installation នៅលើកំរាលឥដ្ឋ ដែលរាយប៉ាយទៅដោយដី និងមានវត្ថុចំនួនបីប្រភេទធ្វើអំពីដីដុតសូនដោយដៃគឺ កាំបិត ចាន និងឆ្អឹង ។ កាំបិតមើលទៅហាក់ដូចជាមុតល្អ ហើយចានមើលទៅប្រើការមិនកើត ព្រោះវាត្រូវបានធ្វើឲ្យឆ្លុះឆ្លាយដោយដៃរបស់សិល្បការិនី ហើយតំណាងឲ្យសំបកគ្រាប់បែកដែលផ្ទុះរួច ។ ចំនែកឯឆ្អឹងវិញ គឺយកចេញពីតុក្កតាដែលម៉ាលីនបានធ្វើឡើង ដែលកាលពីតូចម៉ាលីនធ្លាប់ធ្វើតុក្កតាពីកំប្លោក ។ *មុខថ្មី* (២០១០) ជារបាំងមុខចំនួនប្រាំបួនធ្វើពីម្នាងសីលា ដែលដាក់ភ្ជាប់ទៅនឹងជញ្ជាំង ។ ម៉ាលីន បានបង្កើតរបាំងមុខទាំងនេះចេញពីផ្នែកផ្សេងៗគ្នានៃមុខ បន្ទាប់មកផ្គុំគ្នាទៅជារបាំងមុខដើម្បីឆ្លុះបញ្ចាំងពីជីវិតបែកខ្ញែកក្នុងអំឡុងពេលសង្គ្រាម និងក្រោយសង្គ្រាម ។

ស្នាដៃនៅចំកណ្តាលនៃពិព័រណ៍នេះគឺ រូបចម្លាក់ខ្លែងមួយមានប្រវែងបួនម៉ែត្រដែលមានឈ្មោះថា *ក្តីសង្ឃឹម* (២០១០)។ ការធ្វើខ្លែង និងបង្ហោះខ្លែងបានរស់រានឡើងវិញប៉ុន្មានទសវត្សក្រោយពេលការលុបបំបាត់វប្បធម៌ក្នុងរបបខ្មែរក្រហម ។ ម៉ាលីនចងចាំពីការបង្ហោះខ្លែង ជាពិសេសនៅចុងរដូវវស្សានិងដើមរដូវប្រាំង ដែលជាពេលវេលាពោរពេញទៅដោយក្តីសង្ឃឹមក្នុងការប្រមូលផលស្រូវ ។ ក្នុងចំណោមខ្លែងខ្នាតធំៗទាំងអស់ មានខ្លែងមួយប្រភេទគេឲ្យឈ្មោះថា ខ្លែងឯក ។ គេច្រើនបង្ហោះខ្លែងឯកនេះនៅពេលយប់ ។ ខ្លែងឯកមានលក្ខណៈពិសេសត្រង់វាមានសំឡេងដ៏ក្រលួចបន្លឺចេញពីឯករបស់វា ។ ឯក ជាបន្ទះឫស្សីដែលបិតយ៉ាងស្តើងដាក់បំពាក់នៅលើក្បាលខ្លែង ។ ដោយឡែក ខ្លែងរបស់សិល្បការិនីរូបនេះ ធ្វើពីស៊េរ៉ាមិច ខុសពីខ្លែងធម្មតាដែលធ្វើពីសូត្រឬក្រដាស ហើយស្រាលនិងជាប់បានយូរ ។ ស្នាដៃខ្លែងឯកឈ្មោះ *ក្តីសង្ឃឹម* នេះគឺផ្ទុយពីសេចក្តីរំពឹងទុករបស់យើង ចំពោះវត្ថុប្រកបដោយភាពសប្បាយ និងកំសាន្តនេះ ។ ដោយមានទំងន់ធ្ងន់ មានពណ៌ខ្មៅ និងមានសភាពស្ងប់ស្ងាត់ ខ្លែងឯកនេះមានកន្ទុយធ្វើពីស៊េរ៉ាមិចដ៏ផុយស្រួយដាក់សន្លូកលើកម្រាលឥដ្ឋ ហើយការហោះហើររបស់វាគ្រាន់តែជាការបំភាន់ភ្នែកតែប៉ុណ្ណោះ។

*ស្នាមរបួស ១-៤* (២០១០) ជាស៊េរីគំនូរខ្មៅដៃដែលគូរយ៉ាងផ្ចិតផ្ចង់ចំនួនបួនផ្ទាំង ។ តាមរយៈស្នាដៃនេះ សិល្បការិនីបានស្រមៃពីទំរង់ផ្ទុះនៃសំណុំគ្រាប់អង្ករ ។ ម៉ាលីនលើកឡើងថា «នៅកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសផ្សេងៗនៅអាស៊ីដែរ គឺមនុស្សធ្វើការដើម្បីបានបាយទទួលទាន  ហេតុដូច្នេះរាងកាយរបស់មនុស្សយើងគឺកើតចេញពីគ្រាប់អង្ករ ។» ការផ្ទុះគ្រាប់អង្ករនេះ គឺតំណាងឲ្យការរួចផុតពីសម្ពាធដ៏តានតឹង ។ អត្ថន័យនៃការផ្ទុះនេះគឺចង់បង្ហាញថា វាជាពេលវេលាមួយដែលត្រូវបើកចំហរ ធ្វើដំណើរ និងសិក្សាស្វែងយល់ ។ ទោះជាយ៉ាងណា ចំណងជើង *ស្នាមរបួស* នេះគឺជាការក្រើនរំលឹកពីអ្វីមួយដែលតែងតែនៅជាប់ជាមួយយើងជានិច្ច ។

**អំពីសិល្បការិនី៖**

យឹម ម៉ាលីន កើតនៅខេត្តបាត់ដំបងក្នុងឆ្នាំ១៩៨២ ហើយបច្ចុប្បន្នរស់នៅក្នុងខេត្តសៀមរាប ។ គាត់បានសិក្សាជំនាញសិល្បៈនៅសាលាហ្វាពន្លឺសិល្បៈក្នុងប្រទេសកម្ពុជា (១៩៩៥-២០០៣) បន្ទាប់មកទទួលបានបរិញ្ញាបត្រសិល្បៈផ្នែកសូនរូប ពីសាលាវិចិត្រសិល្បៈនៃទីក្រុងកង់ (Caen la mer) នៅឆ្នាំ ២០១០ ។ ម៉ាលីនបានចូលរួមនៅក្នុងពិព័រណ៍សិល្បៈជាច្រើននៅក្នុងប្រទេសបារាំង និងកម្ពុជា ។ *ការចងចាំ* គឺជាពិព័រណ៍តែម្នាក់ឯង លើកទីមួយរបស់ម៉ាលីន ។

**អំពី ស-សបាសាក់៖**

ស-សបាសាក់ គឺជាវិចិត្រសាលនិងមណ្ឌលធនធានមួយ ដែលប្តេជ្ញាក្នុងការបង្កើត សម្របសម្រួល និងចែករំលែកវប្បធម៌ទស្សសិល្បៈសហសម័យនៅក្នុងនិងចេញពីប្រទេសកម្ពុជា ។

**ព័ត៌មានលំអិត៖**

ពិព័រណ៍៖ *ការចងចាំ* ដោយ យឹម ម៉ាលីន
បើកសម្ពោធ៖ ថ្ងៃទី ៧ ខែ មេសា វេលាម៉ោង ៦ ដល់ ៨ ល្ងាច
ពិព័រណ៍បើក៖ ពីថ្ងៃទី ៧ ខែ មេសា ដល់ ថ្ងៃទី ៨ ខែឧសភា
ម៉ោងទស្សនា៖ ថ្ងៃព្រហស្បតិ៍ និងសុក្រ ម៉ោង ២-៦ ល្ងាច ថ្ងៃសៅរ៍ និងអាទិត្យ ម៉ោង ១០ ព្រឹក - ៦ ល្ងាច
ទីតាំង៖ ស-សបាសាក់ នៅផ្ទះលេខ ១៨ ជាន់ទី២ មហាវិថីសុធារស ភ្នំពេញ
គេហទំព័រ៖ www.sasabassac.com

**ទំនាក់ទំនង៖**

អេរីន ឃ្លីសុន នាយកផ្នែកសិល្បៈនៃស-សបាសាក់
ទូរសព្ទ័ +៨៥៥ (០)១២ ៥០៧ ៩១៧ ឬ អ៊ីមែល erin@sasabassac.com